# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០៣២/០៧ របក.អគគ**

**របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ តុលា ឆ្នាំ ២០០៧របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌និងទិសដៅសម្រាប់អនុវត្តបន្ត**

ក្នុងខែ តុលា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាព សម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោង ជា អង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួល ខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ក. <u>ការងាររដ្ឋបាល</u>

-ផ្ញើលិខិតស្នើទៅក្រសួងពាក់ព័ន្ធ សុំចាត់តាំងតំណាង ១ រូប ជាសមាជិកក្រុមការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោង ១៤:៣០នាទី

-ផ្ញើលិខិតអញ្ជើញចូលរួមពិភាក្សាលក្ខណៈវិនិច្ឆ័យ និងស្តង់ដាតុលាការគំរូ ពីថ្ងៃទី ០៥-០៨ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅសាលប្រជុំអង្គភាពគ្រប់គ្រងគម្រោង

-ផ្ញើលិខិតស្នើសុំផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍វាយតម្លៃហិរញ្ញប្បទានសម្រាប់ប្រទេសកម្ពុជា (ជាមបៀដ៏ Country Assistance Evaluation)របស់ក្រុមវាយតម្លៃឯករាជ្យ (Cambodia Evaluation Group, IEG)នៃធនាគារពិភពលោក

ខ. <u>ការងារកំណែទម្រង់</u>

-ប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោង ១៤:៣០នាទី

-ប្រជុំមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង រៀបចំធ្វើបច្ចុប្បន្នភាពកម្មវិធីសកម្មភាព និងកម្មវិធីការងារ និង រៀបចំការប្រជុំរបស់ក្រុមការងារបច្ចេកទេសចម្រុះ TWG/Model Court

-ប្រជុំអនុក្រុមការងារបច្ចេកទេសចម្រុះទី ៤

-ប្រជុំកែសម្រួលនីតិវិធីនៃការតាក់តែងច្បាប់ ជាមួយក្រុមការងារទីស្ដីការគណៈរដ្ឋមន្ត្រី

-រៀបចំតារាងអនុវត្តការងារកំណែទម្រង់ច្បាប់ និងតុលាការ សម្រាប់ឆ្នាំ២០០៧-២០០៨

-ចូលរួមពិភាក្សាជាមួយអ្នកតំណាង UNHCHR លើការបន្តនិរន្តភាពគម្រោងលើកកំពស់សិទ្ធិមនុស្សនៅ មូលដ្ឋាន

-ជួបពិភាក្សាជាមួយក្រុមហ៊ុនរៀបចំ Database បណ្ដុះបណ្ដាលសិទ្ធិមនុស្ស (Human Right Training)

-ទទួលជួបពិភាក្សាជាមួយក្រុមការងារវាយតម្លៃការអនុវត្តគម្រោង CCJAP III នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧

-ទទួលជួបក្រុមការងារ UNDP រាយការណ៍ពីលទ្ធផលនៃការអនុវត្តគម្រោងសិទ្ធិទទួលបានយុត្តិធម៌ (Access to Justice) នៅថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០៧។

គ. <u>ផ្សេងៗ</u>

-ចូលរួមសិក្ខាសាលាផ្សព្វផ្សាយការប្រើប្រាស់អក្សរក្រមខ្មែរក្នុងប្រព័ន្ធកំព្យូទ័រ (UNICODE) នៅថ្ងៃទី ០២ ខែតុលា ឆ្នាំ២០០៧ នៅសណ្ឋាគារ SUNWAY

-ចូលរួមសិក្ខាសាលាស្ដីពីការវាយតម្លៃលើការអនុវត្តគម្រោង PMG ក្រោមអធិបតីភាពរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៧ នៅ សណ្ឋាគារ Inter-Continental

-ចូលរួមអន្តរក្រសួងពិភាក្សាសេចក្ដីព្រាងច្បាប់ស្ដីពីទូរគមនាគមន៍។

**២-សន្និដ្ឋាន**

ក្នុងខែ តុលា ឆ្នាំ ២០០៧ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមាន អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមាន អង្គភាពគ្រប់គ្រង គម្រោងជាអង្គភាពប្រតិបត្តិ បានបន្តកិច្ចការពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការទៅតាមអាទិភាពដែលបានកំណត់ ដោយផ្ដោតជាសំខាន់ ទៅលើការជម្រុញការអនុវត្តគម្រោង ស្ដីពីការពង្រីកបន្ថែមតុលាការគំរូ និងការរៀបចំប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ និងកិច្ចការរបាយការណ៍ដែលត្រូវរៀបចំសម្រាប់ បំណាច់ឆ្នាំ២០០៧ ក៏ដូចជាការងារកែទម្រង់ច្បាប់ និងតុលាការ ជារួម តាំងពីឆ្នាំ២០០៣-២០០៨។

៣-ទិសដៅអនុវត្តក្នុងខែបន្ត

-រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ នៅថ្ងៃទី ០៥-០៨ ខែវិច្ឆិកា ឆ្នាំ២០០៧

-
រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅខេត្តមណ្ឌលគីរី

-រៀបចំកិច្ចប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-ពិភាក្សាជាមួយវិទ្យាស្ថានដាណឺម៉ាក ដើម្បីសិទ្ធិមនុស្ស (DIHR) អំពីកិច្ចសហការរវាងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពគ្រប់គ្រងគម្រោង និងវិទ្យាស្ថានដាណឺម៉ាក ដើម្បីសិទ្ធិមនុស្ស សម្រាប់ឆ្នាំ២០០៨

-ពិភាក្សាជាមួយនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីរៀបចំវគ្គ បណ្តុះ -បណ្តាល ស្តីពី ថវិកាកម្ម និងផែនការកម្ម សម្រាប់វិស័យច្បាប់ និងតុលាការ។

-ទទួលជួបគណៈប្រតិភូនៃឧត្តមក្រុមប្រឹក្សាសារការីប្រទេសបារាំង
ដើម្បីពិភាក្សាអំពីសេចក្តីព្រាង អនុក្រឹត្យបង្កើតសាលាភូមិន្ទសារការី និងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការី។

អ្នកធ្វើរបាយការណ៍

ហ៊្វីង សុកុល

បានឃើញ និងឯកភាព
នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង